# ចម្លាក់គ្រុឌក្នុងសិល្បៈខ្មែរ

គ្រុឌ គឺជាឈ្មោះមួយនៃសត្វបក្សីនៅក្នុងរឿងទេពកថារបស់ឥណ្ឌា (Mahabharta) និងជាយាន ជំនិះរបស់ព្រះវិស្ណុ និងជាសត្រូវស្ជួរពូជនឹងសត្វនាគ ហើយគ្រុឌក៏ជានិមិត្តរូបនៃកម្លាំង ភាពអង់អាចក្លាហាន និងភាពរហ័សនៃការហោះហើរ ព្រមទាំងអាចហោះទៅកាន់ឋានសួគ៌ និងអាចហោះទំលុះមេឃបាន។ ជាទូទៅគ្រុឌបង្ហាញក្នុងសិល្បៈខ្មែរមានដងខ្លួន និងដៃដូចជាមនុស្ស មានចំពុះ ស្លាប ជើង និងក្រញ៉ាំដូចជាសត្វឥន្ទ្រី។[១]

ពាក្យថា "គ្រុឌ" មកពីពាក្យសំស្ក្រឹតមាននន័យថា គរុឌ ឬ គរូឌ (Garuda) ហើយពាក្យបាលីមានន័យថា គុរុឡ "គ្រុឌ សត្វសសេះ"[២]។ តាមរយៈអត្ថបទទេពកថាឥណ្ឌាបានបរិយាយថា គ្រុឌមានឪពុកឈ្មោះកស្សប (Kasyapa) មានប្រពន្ធពីរឈ្មោះនាងកទ្រូ (Kadrū) និងនាងវិនតា (Vinatā) ដែលត្រូវជាកូនស្រីរបស់ទក្ស (Daksha) និងជាម្តាយរបស់សត្វគ្រុឌ។ គ្រុឌមានភរិយាឈ្មោះថា ឧណ្ណតិ ឬ វិនាយកា មានបុត្រមួយឈ្មោះថា សម្បាតិ ខ្លះយល់ថាជតាយុក៏ជាបុត្ររបស់គ្រុឌដែរ។ ក្រៅពីនេះសត្វគ្រុឌ ក៏មានបង្ហាញតាមរឿងទេពកថាដូចជារឿងកូរសមុទ្រទឹកដោះ រឿងក្រឹស្ណៈបង្ក្រាបនាគកាល្យណ៍ និងរឿងគ្រុឌជាយានជំនិៈរបស់ព្រះវិស្ណុ ជាដើម។

ចម្លាក់គ្រុឌនៅក្នុងសិល្បៈខ្មែរ គឺភាគច្រើនទទួលឥទ្ធពលពីឥណ្ឌាដែលហូរចូលមកក្នុងប្រទេសខ្មែតាំងពីដើមនៃគ្រឹស្តករាជ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺខ្មែរបានកែច្នៃឱ្យក្លាយទៅជាសិល្បៈរបស់ខ្លួន។ ក្នុងនោះចម្លាក់សត្វគ្រុឌត្រូវបានបង្ហាញឡើងស្ទើរតែគ្រប់កន្លែងតាមរយៈរូបបដិមាមានទាំងថ្ម និងសំរិទ្ធ និងសំណង់លម្អស្ថាបត្យកម្មនៃប្រាសាទដូចជាលើផ្តែរ សសរផ្អោប ហោងជាង បង្កាន់ដៃ និងមេដៃយ៉ុង។ ជាទូទៅគ្រុឌបង្ហាញជារូបកិន្នរមានដុះក្បាលពោះដែលស្រដៀងទៅនឹងលក្ខណៈរបស់ឥណ្ឌា និងអាចឱ្យយើងដឹងពីការចំលងសិល្បៈពីឥណ្ឌារួមមាននៅបណ្តារូងភ្នំចុងក្រោយនៅ Ajanta និងបណ្តារូងភ្នំ ដំបូង។

---

[១] Boisselier Jean 1956:105

[២] ជួន ណាត ២៥១២:១៥៦

អត្ថបទដោយៈ ថាន់ មនោមយិទ្ធិ

នៅ Ellora។[៣] គ្រុឌចាប់ផ្តើមមានវត្តមានដំបូងក្នុងអាណាចក្រខ្មែរនាសតវត្សទី៧ នៃគ.ស ស្ថិតនៅក្នុងរចនាបថសម្បូរព្រៃគុកនៃប្រាសាទសម្បូរព្រៃគុក ដែលបង្ហាញក្នុងមេដៃយ៉ុង នៅចំកណ្តាលអង្កត់ធ្នូ សក់មានផ្នត់ធំៗ ច្រមុះវែងធំៗ ភ្នែកលៀន និងមានពាក់ក្រវិលរាង មូលៗ ប៉ុន្តែហាក់សំដែងនូវភាពគ្មានសម្រស់ និងមានទ្រទ្រាយជាមនុស្សមាឌក្រអាញ ពោះរាងធ្លាក់រយាក និងមានសត្វម្ករនៅសង្ខាង ថែមទាំងក្បាច់ផ្កាវំយោងនៅក្រោមដងធ្នូ នៃផ្តែរ (រូបលេខ១)។



រូបលេខ១. ចម្លាក់គ្រុឌបង្ហាញ ក្នុងមេដៃយ៉ុងនៅផ្នែកកណ្តាលនៃអង្កត់ធ្នូក្នុងរចនាបថសំបូរព្រៃគុក (ប្រភាព:សារមន្ទីរជាតិភ្នំពេញ)

ក្នុងសម័យអង្គរដើមសតវត្សទី៩ គ្រុឌបង្ហាញឡើងលើផ្តែរនៅចំពាក់កណ្តាលអង្កត់ធ្នូ ដែលពេលនោះចម្លាក់គ្រុឌដើរតួនាទីជាយានជំនិះរបស់ព្រះវិស្ណុផងដែរ។ ជាស្តែងមាន ដូចជា នៅប្រាសាទព្រះគោផ្តែរមានសភាពល្អ និងការឆ្លាក់គួរឲ្យចាប់អារម្មណ៍ គឺបង្ហាញពី ព្រះវិស្ណុជិះលើគ្រុឌចាប់នាគពីរក្បាលដែលខ្លួននាគគេឆ្លាក់ជាទម្រង់អង្កត់ធ្នូ ក្បាច់វំយោលផ្កា និងក្បាច់ភ្ញីភ្ញើងផ្សេងៗទៀតផង (រូបលេខ២)។ ចំណែកឯផ្ទាំងចម្លាក់ប្រាសាទអង្គរវត្តនៅថែវ ខាងជើងប៉ែកខាងលិច និយាយពីរឿងរ៉ាវធ្វើសង្គ្រាមរបស់ព្រះវិស្ណុ ឬ ក្រឹស្នៈជាមួយអសុរៈ (Asura) បង្ហាញពីព្រះវិស្ណុជិះលើគ្រុឌដែលកំពុងប្រយុទ្ធជាមួយកងទ័ពអសុរៈ (រូបលេខ៣)។ ព្រមជាមួយគ្នានោះ ប្រាសាទព្រះខ័នគ្រុឌបង្ហាញជាក្បាច់លម្អដែលឆ្លាក់នៅតាមជ្រុងនៃ ផ្នែកខាងលើជញ្ជាំង និងបង្ហាញក្នុងទម្រង់ដ៏ធំមហិមា និងមានភាពទាក់ទាញជាងគេ

[៣]Boisselie Jean 1950:58

បំផុតដែលគ្រុឌសម្រាប់លម្អស្ថាបត្យកម្ម ជាអ្នកទ្រ និងការពាររបងជញ្ជាំងព័ទ្ធជុំវិញប្រាសាទព្រះខ័ន (រូបលេខ២៤)។ ចំណែកឯគ្រុឌនៅតាមជណ្តើរអក្សរកណ្តាលនៃទីព្រលានជល់ដំរី ក៏បានបង្ហាញជាលក្ខណៈក្បាច់លម្អមានទម្រង់ធំៗនៅតាមជញ្ជាំងដូចនៅប្រាសាទព្រះខ័នដែរ និងមានរំយោងផ្កាតាមចន្លោះ នៃរូបគ្រុឌនិមួយៗ (រូបលេខ២៥)។



រូបលេខ២២. ចម្លាក់គ្រុឌជាយានជំនិះរបស់ព្រះវិស្ណុនៅលើផ្តែរប្រាសាទព្រះគោ



រូបលេខ២៣. ព្រះវិស្ណុជិះលើគ្រុឌកំពុងប្រយុទ្ធជាមួយកងទ័ពអសុរៈនៅថែវខាងជើងប៉ែកខាងលិចនៃប្រាសាទអង្គរវត្ត



រូបលេខ២៤. ចម្លាក់គ្រុឌមានទំហំធំលម្អតាមជញ្ជាំង កំពែងទី៤នៅប្រាសាទព្រះខ័ន

អត្ថបទដោយ៖ ថាន់ មនោមយិទ្ធិ



រូបលេខ២៥. ចម្លាក់គ្រុឌមានទំហំលម្អតាមជញ្ជាំងជណ្ដើរអក្សរកណ្ដាលនៃទីព្រលានជល់ដំរី

ក្នុងនោះរូបព្រះវិស្ណុជិះលើគ្រុឌក៏មានបង្ហាញតាមរយៈរូបបដិមាធ្វើពីសំរិទ្ធ ដោយព្រះអង្គមានព្រះហស្តបួនកាន់នូវកេតនភ័ណ្ឌខុសៗគ្នារួមមាន ព្រះហស្តស្ដាំផ្នែកខាងលើកាន់កងចក្រ ផ្នែកខាងក្រោមកាន់ដាវ ឬ ដំបង រីឯព្រះហស្តឆ្វេងផ្នែកខាងលើកាន់អាវុធមុខបី និងផ្នែកខាងក្រោមកាន់ខ្យងសង្ខ័ ឬ ផ្កាឈូក។ ម្យ៉ាងទៀតព្រះអង្គឈរលើស្មាគ្រុឌមានសំលៀកបំពាក់ ដូចជាអ្នករបាំសម័យបច្ចុប្បន្ន និងមានគ្រឿងអលង្ការលម្អជាច្រើន។ ចំណែកគ្រុឌវិញដៃពីរលើកឡើងលើសំលៀកបំពាក់ ដូចជាព្រះវិស្ណុដែរលម្អដោយស្រង់កជំមួយខ្សែ និងបង្ហាញក្បាច់លម្អយ៉ាងស្អាតគឺបញ្ចេញនូវភាពអស្ចារ្យរបស់សត្វនេះ (រូបលេខ២៦)។



រូបលេខ២៦. រូបបដិមាព្រះវិស្ណុជិះលើគ្រុឌធ្វើពីសំរិទ្ធ
(ប្រភព: សារមន្ទីរជាតិភ្នំពេញ)

រហូតមកដល់សម័យក្រោយអង្គរ ចាប់ពីសតវត្សទី១គឺមានការផ្លូរសាសនាពីព្រហ្មញ្ញសាសនាមក ព្រះពុទ្ធសាសនាថេរវាទ ហើយរាល់សម្ភារៈសំណង់ស្ថាបត្យកម្មជាច្រើនដែលសាងក្នុងសម័យនេះ ត្រូវបានផ្លាស់ប្ដូរជាសំណង់វត្តអារាមធ្វើពី

អត្ថបទដោយ៖ ថាន់ មនោមយិទ្ធិ

ឈើ។[៦] ក្នុងនោះចម្លាក់គ្រុឌត្រូវបានបង្ហាញជាក្បាច់លម្អធ្វើពីឈើតាមក្បាលសសរ ហោងជាងនៃព្រះវិហារ និងផ្ទាំងគំនូរដែលនិយាយពីរឿងផ្សេងៗ។ រូបគ្រុឌលម្អនៅលើហោងជាង ធ្វើពីឈើលើព្រះវិហារនៃវត្តរាជបូរណ៍សតវត្សទី១៩ បង្ហាញក្នុងទម្រង់ព្រះវិស្ណុជិះគ្រុឌ(រូបលេខ២៧)។ ចំណែកគ្រុឌលើផ្ទាំងគំនូរមានបង្ហាញនៅថែវខាងជើង នៃព្រះវិហារព្រះកែវមរកតក្នុងរឿងរាមកេរ្តិ៍ត្រង់ឈុតគ្រុឌចុះមកដេញកំចាត់ពស់ ដោយចាប់ពស់នឹងដៃទាំងពីរ (រូបលេខ២៨)។



រូបលេខ២៧. ចម្លាក់ព្រះវិស្ណុជិះគ្រុឌលើហោងធ្វើពីឈើនៃព្រះវិហារវត្តរាជបូរណ៍ ខេត្តសៀមរាប



រូបលេខ២៨. គ្រុឌលើផ្ទាំងគំនូរបង្ហាញនៅថែវខាងជើងនៃព្រះវិហារព្រះកែវមរកត

[៦] Ang Chouléan 1998:75

អត្ថបទដោយ៖ ថាន់ មនោមយិទ្ធិ

*ជារូបសត្វគ្រុឌ គឺជាសត្វបក្សីដែលជានិមិត្តរូបនៃកំលាំង ថាមពល នៃភាពអង់អាចក្លាហាននៅក្នុងការហោះហើរ។ នៅក្នុងសិល្បៈខ្មែរ គ្រុឌមានតួនាទីច្រើនយ៉ាង គឺជាយានជំនិះរបស់ព្រះវិស្ណុ ជាទម្រ ជាការលម្អទៅលើផ្នែកផ្សេងៗនៃសំណង់ស្ថាបត្យកម្មទាំងនៅលើសំណង់ប្រាសាទ និងសំណង់ព្រះវិហារ។ ចម្លាក់គ្រុឌដែលបង្ហាញនៅក្នុងសំណង់ស្ថាបត្យកម្មប្រាសាទខ្មែរជាលើកដំបូងគេ ឃើញមានវត្តមានក្នុងរចនាបថសំបូរព្រៃគុកនៅចំផ្នែកកណ្តាលនៃផ្តែរទ្វារស្ថិតនៅក្នុងមេដៃយ៉ុងដែលពេលនេះ មើលទៅគ្រុឌគ្មានចលនាគ្មានសម្រស់។ ចូលមកដល់សម័យអង្គរចម្លាក់គ្រុឌមានការវិវត្តន៍បន្តិចម្តងៗ ដោយគ្រុឌពេលនេះធ្លាក់ជាតួនាទីជាយានជំនិះរបស់ព្រះវិស្ណុ និងជាគ្រឿងលម្អសំណង់ស្ថាបត្យកម្មរបស់ប្រាសាទ។ រហូតមកដល់សម័យក្រោយអង្គរគ្រុឌក៏នៅតែជាការពេញនិយមយកមកធ្វើជាគ្រឿងតុបតែងលម្អក្នុងសំណង់នានាមានដូចជា សំណង់ព្រះវិហារ និងវត្តអារាម។ ក្រៅពីនេះរូបគ្រុឌគឺមានការលម្អដោយគំនូរដែលគូរនៅលើជញ្ជាំង ឬពិដានដែលនិយាយពីរឿងរ៉ាវពុទ្ធប្រវត្តិ ឬក៏រឿងព្រេងទេវកថាផ្សេងៗ។*

## *ឯកសារយោង*

*ជួន ណាត, វចនានុក្រមខ្មែរ, បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ, ពុទ្ធសករាជ ២៥១២, ទំព័រ ១៥៦។*

Boisselier Jean
1956. Trends In Khmer, Presses Universitaires de France, Art, p.105.

Boisselie Jean
1950. Garda dans L'art Khmer, BEFEO, tome XLIV, p.58.

Ang Chouléan
1998. Eric Prenowitz and Ashley Thompson, Past, Present and Future, APASARA, Royal Government of Cambodia, Second Revised Edition, p.75.

*អត្ថបទដោយៈ ថាន់ មនោមយិទ្ធិ*